# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៣៥ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពីការកែសម្រួលការរៀបចំ និង ការប្រព្រឹត្តិទៅ

## នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការសម្រាប់គោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃការងាររបស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា ១.-**

អនុក្រឹត្យនេះ កែសម្រួលការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ «**គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**» ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ។

**មាត្រា ២.-**

«**គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**» ហៅកាត់ «**គសហ**» មានភារកិច្ចដឹកនាំរៀបចំ សម្របសម្រួលការអនុវត្ត និង តាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល មានជាអាទិ ការងារពាក់ព័ន្ធនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ការអភិវឌ្ឍវិស័យឯកជន ព្រមទាំង

មានភារកិច្ចសម្របសម្រួលរាល់កិច្ចសហប្រតិបត្តិការសំរាប់ការអភិវឌ្ឍន៍ ឬ សំរាប់កំណែទម្រង់នៃវិស័យសេដ្ឋកិច្ច និង នៃវិស័យហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍ ។

**មាត្រា ៣.-**

**គសហ** មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២- | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣- | ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | អនុប្រធានប្រចាំការ |
| ៤- | រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៥- | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ៦- | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ៩- | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១០- | រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១១- | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | សមាជិក |
| ១២- | រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម | សមាជិក |
| ១៣- | រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ១៤- | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥- | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក ។ |

**មាត្រា ៤.-**

**គសហ** ប្រើប្រាស់អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន ។

**មាត្រា ៥.-**

ដើម្បីបំពេញបេសកកម្ម និងសម្រេចភារកិច្ចដូចមានចែងក្នុងមាត្រា ២ ខាងលើ **គសហ** អាចបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់តាមវិស័យ រួមមានជាអាទិ៍ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន ឬ បង្កើតគណៈកម្មាធិការដឹកនាំការងារ ឬ អនុគណៈកម្មាធិការ ឬ ក្រុមការងារបច្ចេកទេសផ្សេងទៀត ទៅតាមការចំបាច់ សម្រាប់ជួយដឹកនាំរៀបចំ សម្របសម្រួលការអនុវត្ត និង តាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់សេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល តាមវិស័យ ឬ អនុវិស័យនីមួយៗ ព្រមទាំងសម្រាប់ជួយសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ ។

**មាត្រា ៦.-**

**គណៈកម្មាធិការដឹកនាំការងារតាមវិស័យ** និង **អនុគណៈកម្មាធិការ** ដែលមានលក្ខណៈអន្តរក្រសួង ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ **គសហ** ។

**មាត្រា ៧.-**

**គសហ** ព្រមទាំង **គណៈកម្មាធិការដឹកនាំការងារតាមវិស័យ** **អនុគណៈកម្មាធិការ** និង **ក្រុមការងារបច្ចេកទេស** មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និង តំណាងសង្គមស៊ីវិល ឱ្យចូលរួមប្រជុំក្នុងឋានៈជាសមាជិក ឬ អ្នកសង្កេតការណ៍ ទៅតាមតម្រូវការចាំបាច់នៃការងារ ។

**មាត្រា ៨.-**

**គសហ** មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬ តំណាងនៃប្រធានស្ថាប័ន ព្រមទាំងមន្ត្រីបច្ចេក-ទេសនៃក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល មកចូលរួមប្រជុំ និង បំពេញការងារ តាមការចាំបាច់ ។

**មាត្រា ៩.-**

- **គសហ** ធ្វើការតាមការអញ្ជើញរបស់ប្រធាន
- **គសហ** ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ប្រធានឧត្តមក្រុម-ប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ និង ប្រធានស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋារាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- ឯកសារ-កាលប្បវត្តិ